


នេះជារូបភាពព្រះវិហារវត្តតាមុំកំពុងកសាងឡើងវិញ បន្ទាប់ពីសង្គ្រាមនៅយៀកណាមខាងត្បូងបានរលត់ហើយ របបសាធារណរដ្ឋធីវ-គី ត្រូវបរាជ័យ ។ ក្នុងសម័យសង្គ្រាម១៩៦០-៧៥ ពួករបបសេរីក៏ដូចរបបកុម្មុយនិស្តសព្វថ្ងៃបានតាំងមូលដ្ឋានទ័ពទ័ពនៅក្នុងវត្តតាមុំ ហើយឆ្លៀតពេលហ្នឹង ពួកគេបានបាញ់ផ្លោងកាំភ្លើងកាណុងចូលក្នុងវត្ត បំណងដើម្បីកំទេចវត្តអារាមខ្មែរក្រោម ។ ដោយឃើញព្រះវិហារបាក់បែកខូចខាត ញាតិញោមពុទ្ធបរិស័ទរួមជាមួយគណៈវត្ត បានរៀបចំជួសជុលកសាងព្រះវិហារឡើងវិញ ទុកសំរាប់ប្រគេនព្រះភិក្ខុសង្ឃធ្វើវត្តបដិវត្តិន៍ និងសង្ឃកម្មនានា ។ វត្តតាមុំ ឃុំតាមុំ ស្រុកអង្កៀង ខេត្តក្រមួនស ប្រទេសកម្ពុជាក្រោម ។ យួនខំហៅតាមខ្មែរថា Giong Rieng ដែលក្លាយមកពីអង្កៀង ។

ដើម្បីធ្វើកិច្ចការនេះឲ្យបានសំរេច ខ្ញុំគោងដឹកនាំរូប «លឹង្គ» ឲ្យទៅដល់មាត់ព្រែក ដើម្បីនាំទៅតាមផ្លូវទឹកចុះរហូតទៅដល់ក្រុងព្រៃនគរ។ គេពិបាកនឹងប្រើរទេះគោក្របីណាស់ ព្រោះវាធ្ងន់ពេក។ ហេតុនេះហើយ ខ្ញុំក៏អំពាវនាវហៅរករទេះម៉្យាងសំរាប់រំអិលលើទឹកព្រែក (un traîneau) ដែលគេផ្ទឹមដោយគោ ។ ក៏ប៉ុន្តែទៅមុខបានប្រមាណ១០០ម៉ែត្រ ស្រាប់តែគោទាំងនោះក្រាញលែងដើរទៅមុខសោះតែម្តង ។ គេក៏ទៅយកក្របីមកផ្ទឹមជំនួសវិញ ក្របីមាឌមាំៗទាំងនោះក៏ក្រាញមិនដើរទៅមុខដូចគោដែរ ។ ដោយយល់ឃើញថាអ្នកតាដ៏សំបើមគួរព្រឺខ្លាច បើសិនណាខ្ញុំមិនអាចរកមធ្យោបាយធ្វើយ៉ាងណានាំដុំថ្មដ៏សែនចចេសរឹងរុះចេញពីទីនេះបានទេនោះ កេរ្តិ៍ឈ្មោះខ្ញុំប្រាកដជាសាបរលាបជាពុំខាន។ ដូច្នេះខ្ញុំក៏ចាត់ចែងឲ្យធ្វើជាស្នែងសែងរំកិលដោយមនុស្ស២០នាក់ ។ យើងក៏បានសំរេចជោគជ័យនាំ«អ្នកតា»ទៅដល់ភូមិ ក៏ប៉ុន្តែគ្មាននរណាម្នាក់យល់ព្រមយក«អ្នកតា»នោះទៅដាក់នៅជិតផ្ទះសំបែងរបស់គេសោះឡើយ ។ ខ្ញុំក៏សំរេចឲ្យគេយកទៅដំកល់ទុកមុខសាលាឃុំ ដែលជាទីកន្លែងខ្ញុំរស់នៅ ដោយដាក់រ៉ែបបណ្តោយតាមផ្លូវលំចូល ។ គេក៏នាំគ្នារៀបដាក់ទទឹងផ្លូវ បន្ទាប់មកខ្ញុំក៏ចាត់ឲ្យរៀបស្របនឹងផ្លូវចូលឡើងវិញ ក្រោយមកពួកគេនៅតែចចេសទាញមកដាក់ទទឹងផ្លូវដដែល ។ ដោយខ្ញុំជជីកសួររកហេតុផលដែលបណ្តាលនាំឲ្យពួកគេមានៈចចេសខុសទម្លាប់ ចំឡែកខុសពីសព្វដងបែបនេះ គេក៏បានពន្យល់មកខ្ញុំវិញថា ៖ ក្នុងករណីទី១ ខ្លួនខ្ញុំផ្ទាល់នឹងត្រូវជម្ងឺអ្វីមួយមកយាយីបៀតបៀនជាពុំខាន់ ដោយការសំដែងនូវក្តីក្តៅក្រហាយមួម៉ៅរបស់អារក្សអ្នកតា ។ ចំណែកខាងលើកទី២វិញ ខ្ញុំចាត់ទុកថា ទង្វើបែបនេះជាការផ្តុយឬល្មើសពីបញ្ជារបស់ខ្ញុំ ក៏ព្រោះតែគេចង់ការពារផលប្រយោជន៍និងក្តីសុខសប្បាយដល់រូបខ្ញុំផងដែរ ។ ប៉ុន្តែបើប្រសិនណាជាខ្ញុំមិនត្រូវការនូវការគាំទ្រការពារ គេក៏មិនអាចធ្វើឲ្យសំរេចបានដែរ ដោយបោះបង់ចោលឲ្យខ្ញុំទទួលទៅតាមវាសនាអាក្រក់ឧបទ្រពចង្រៃ វិនាសហិនហោចតាមយថាកម្មទៅចុះ ។ បន្ទាប់ពីពេលនោះមក ខ្ញុំក៏បានទៅពិនិត្យដីទួលដំបូកមួយកន្លែង ដែលខ្ញុំបានចាត់ចែងជីកកកាយរុករកក្នុងដីនូវបុរាណវត្ថុ ។ នៅលើកំពូលនៃដីដំបូកនេះ ហើយនៅត្រង់គល់ឈើមួយដើមធំ មានផ្ទាំងថ្មម្យ៉ាងរឹងបំផុត ( un bloc de granit) គ្មានរាងរៅឥតទ្រង់ទ្រាយអ្វីទេ ដែលគេជឿជាក់ថា មានព្រលឹងខ្មោចព្រាយអ្នកតាអារក្ស ប្រកបដោយកំហឹងឃ្លានិស តាមបំផ្លាញដោយក្តីមួម៉ៅក្តៅក្រហាយ ហើយដែលអ្នកស្រុកទូទៅក្នុងតំបន់នោះបានដឹងច្បាស់គ្រប់ៗគ្នា ។ ខ្ញុំក៏ចេញបង្គាប់បញ្ជាមិនឲ្យនរណារំកិលផ្ទាំងថ្មនេះចេញពីទីនោះជាដាច់ខាត ដើម្បីចៀសវាងជាចាំបាច់ក្នុងការរក្សានូវសេចក្តីសុខសប្បាយដល់ពពួកកម្មករគូលីទាំងឡាយ ។ នាថ្ងៃដដែលហ្នឹង ខ្ញុំក៏ប្រទះឃើញនៅលើដីទួលដំបូកនោះផងដែរ នូវមនុស្សបីនាក់ដែល

កំពុងរៀបចំបន់ស្រន់ថ្វាយដង្វាយដល់អ្នកតា ។ ពួកគេទើបនឹងរៀបចំនៅទីសក្ការៈបូជានាទីជនបទស្រុកស្រែចំការនេះនូវ ៖ទាខ្វៃមួយ, ស្រារមួយដប, ផ្លែឈើខ្លះៗ, បាយមួយចាន ហើយនិងធូបមួយដុំ ។ ពេលនោះពួកគេក៏ក្រោកឈរឡើង រៀបចំចាកចេញពីទីនោះ រួចពួកគេក៏បាននិយាយរ៉ាយរ៉ាប់ប្រាប់ខ្ញុំថា នាថ្ងៃមួយឪពុករបស់ពួកគេបានទៅមើលកិច្ចការដែលខ្ញុំបានចាត់ចែងឡើងនោះ ( ការរំកិលអ្នកតាមហាលិង្គ) គាត់ក៏ស្រាប់តែឈឺចុកចាប់ធ្វើទុក្ខបុកម្នេញ កើតមានឡើងភ្លាមមួយរំពេជហើយមិនទាន់ឃើញមានការជាសះស្បើយនៅឡើយ ។ នោះប្រាកដជាអ្នកតាចាប់កំហុសចាប់ទោសអួសដំណើរយ៉ាងកាចសាហាវ យ៉ាងអាក្រក់អាក្រីដោយពិតប្រា-កដហើយ ។ ដល់វេនខ្ញុំមកដល់ហើយ ខ្ញុំក៏វិលត្រឡប់ទៅកាន់ទីនោះសារឡើងវិញ ដោយមានជនជាតិខ្មែរម្នាក់មានថាច់-វង្ស បានទៅជាមួយខ្ញុំផងដែរ រួចគាត់បានសុំអនុញ្ញាតពីខ្ញុំ ឲ្យគាត់សុំប្តឹងតវ៉ាចំពោះសារណាវត្ថុនោះផង ។ ខ្ញុំឃើញគាត់និយាយតវ៉ាដោយការខ្សិបខ្សៀវយ៉ាងយូរវែងអន្លាយជាមួយថ្មអ្នកតានោះ។ គាត់និយាយទៅរកអ្នកតាដោយសម្លេងតិចៗ ប្រកបដោយវាចានិងកាយវិការបញ្ចុះបញ្ចូលឲ្យជឿជាក់មកលើរូបគាត់ ។ គាត់ពន្យល់ទៅអ្នកតាថា រូបគាត់ថាច់-វង្សជាជនកូនចៅក្រីក្រលំបាកណាស់ ហើយគាត់មានការស្រេកឃ្លានជាពន់ពេក ។ ចំណែកខាងអ្នកតាដ៏មានឥទ្ធិឫទ្ធិដោយការភ័យខ្លាច និងដោយការគោរពបូជាពីសំណាក់សាធារណជនទូទៅ អ្នកតាមានអ្វីៗសព្វបែបយ៉ាងសំបូរហូរហៀរឥតខ្វះ ។ ដូច្នេះហើយ គាត់ក៏តាំងស្នើសុំដោយក្តីគោរពឱនលំទោន សុំអ្នកតាមេត្តាចែករំលែកនូវគ្រឿងបូជាទាំងអំបាល់ម្យាណដែលសប្បុរស ជនបាននាំយកមកថ្វាយនោះឲ្យដល់រូបគាត់ផងដោយក្តីអនុគ្រោះ ។ ខ្ញុំសន្និដ្ឋានថា ប្រហែលជាអ្នកតាយល់ព្រមតាមសេចក្តីស្នើសុំរបស់របស់ថាច់-វង្សនោះហើយ បានជាខ្ញុំឃើញគាត់លើកដបស្រា-សធីកក្អឹកៗ កាច់ជើងទានិងកទាទុកឲ្យអ្នកតាដោយជឿស៊ុប ហើយរបស់របរក្រៅពីនោះគាត់ប្រមូលយកខ្ទេច ។ រឿងរ៉ាវពីអ្នកតានេះ បង្ហាញបញ្ជាក់ប្រាប់យើងឲ្យដឹង ពីសតិសម្បជញ្ញៈដ៏ធម្មតាងាយយល់បំផុតចំពោះប្រជាកសិករខ្មែរ ក៏ដូចជនជាតិភាគច្រើនដូច្នោះដែរ ពោលគឺត្រឹមតែសុំប្រកបរបរកសិកម្ម ដោយសុខសប្បាយតែប៉ុណ្ណោះ ។ ពួកគេម្នាក់ៗ ទោះបីខ្មែរឬយួនក៏ដោយ មានឫកពារចរិយាគួរឲ្យស្រឡាញ់រាប់អាន និងគួរឲ្យគោរពយកចិត្តទុកដាក់ទៀតផង ។ នៅពេលណាដែលគេនិយាយអំពីការរស់នៅយ៉ាងធម្មតា យ៉ាងសាមញ្ញបំផុតរបស់ពួកគេវិញ ពួកគេតែងនាំគ្នាអង្គុយលើកឡេលធីកតែជជែកពីរឿងផ្សេងៗដោយស្មោះត្រង់ ដោយគ្មានកល្បល្បិច ។ ឯអ្នកស្តាប់ក៏

ប្រុងត្រចៀកស្តាប់ដោយក្តីរីករាយ និងដោយការយកចិត្តទុកដាក់ ។ ត្រង់នេះខ្ញុំសង្កេតឃើញដោយជឿងឆ្ងល់ដោយក្តីចម្លែកថា ពួកគេទាំងឡាយនោះមានលក្ខណៈមិនខុសគ្នាទាល់តែសោះ នឹងកសិករនៅតាមជនបទជិតឆ្ងាយនាប្រទេសបារាំងរបស់យើង ហាក់បីដូចជាពួកគេបានថ្លឹងពិចារណារួចជាស្រេច ដោយឥតមានការសង្ស័យក្នុងការបង្ហាញនូវអមិត្តភាព នូវការប្រទូស្តរាយចំពោះជនជាតិបរទេសសោះឡើយ ។ ជាច្រើនលើកច្រើនដងណាស់មកហើយ ដែលខ្ញុំរមែងធ្វើដំណើរសព្វទិសទី ដើរ ជិះសេះ ជិះរទេះ ឬជិះសំប៉ានទៅ គ្រប់ខេត្តខ័ណ្ឌទាំងឡាយនៃដែនដីកូសាំងស៊ីនដោយព្រមទទួលតាមសេចក្តីអញ្ជើញដ៏ស្មោះស្ម័គ្រពីវត្តអារាមនានារបស់ខ្មែរ ។




រូបថតព្រះវិហារវត្តនិគ្រោធ កំពង់ក្សាន្ត ខេត្តព្រះត្រពាំង ( ប្រទេសកម្ពុជាក្រោម

ពួកគេប្រញាប់ប្រញាល់រត់រកបេះផ្លែដូងខ្ចីយកមកឲ្យខ្ញុំផឹក ដើម្បីបំបាត់ការស្រេក ។ ចំណែកខាងខ្ញុំវិញ ខ្ញុំបានជូនដល់ពួកគេនូវទៀនធូបនិងកញ្ចប់តែ។ ក្នុងផ្ទះជនដែលទទួលឲ្យខ្ញុំស្នាក់អាស្រ័យ គេក្រាលកន្ទេលទទួលខ្ញុំសំរាន្តសំរាកកាយ ។ នារដូវក្តៅពេលថ្ងៃត្រង់ក្តៅខ្លាំង ប្រកបដោយវាយោដ៏បរិសុទ្ធបក់រំភើយៗមកម្តងម្កាល ខ្ញុំហា

ក់ដូចជាមានអារម្មណ៍ ថាគ្មានពេលណាហើយដែលស្ងប់ស្ងាត់ក្នុងសតិអារម្មណ៍ជាជាងពេលនេះទេ ។ ខ្ញុំគេងទំរេតលើគ្រែទំរេតធ្វើអំពីឫស្សីនៅលើផ្ទះខ្មែរទាំងនោះសង់ខ្ពស់ពីដី ។ ខ្ញុំសង្កេតមើលព្រះសង្ឃប្រកបដោយស្បង់ជីពរពណ៌លឿងទុំ កំពុងនិមន្តដោយស្រ៉ូតត្រូតគំនៅតាមទីធ្លា... ម្តងៗខ្យល់រំភើយតិចៗបានបោកបក់យោលកញ្ចុំផាងដូងរវិចៗ ។ ជាញយដង ខ្ញុំតែងទៅកាន់សាលារៀននៅតាមវត្តនានានៅពេលក្មេងៗចេញលេងម្តងៗ ដោយឮសម្លេងជជែកគ្នារអ៊ូៗតិចៗ ធ្វើឲ្យខ្ញុំចាប់អារម្មណ៍នឹកឃើញថា នៅទីនេះបញ្ហាសិក្សាធិការបានចោទយ៉ាងខ្លាំងណាស់ទេតើចំពោះសហគមជនជាតិភាគតិចខ្មែរនៅដែនដីកូសាំងស៊ីននេះ! ។ សហគមខ្មែរនេះមានលក្ខណៈដូចគ្នាទាំងអស់ (un ensemble homogène) ទាំងចិត្តគំនិតទាំងទម្លាប់រស់នៅ ទាំងភាសា ទាំងសាសនា ទាំងទំនៀមទំលាប់ ទាំងប្រពៃណី...។ ដោយតាំងចិត្តយ៉ាងខ្ជាប់ខ្ជួនក្នុងកិច្ចថែរក្សានូវទំនៀមទម្លាប់របស់ពួកគេយ៉ាងម៉ឺងម៉ាត់នោះម្លោះហើយពួកគេស្ទប់ខ្ចើមមិនចង់បញ្ជូនបុត្រធីតារបស់ពួកគេទៅកាន់សាលារៀនបារាំង-យួន (Ecole Franco-Annamite) ទោះបីភាសាបារាំង-ខ្មែរ (Ecole Franco-Khmère) មានចំនួនតិចតួចក៏ដោយ ។ រហូតមកដល់ពេលនេះ គេបានសាកល្បងរិះរកមធ្យោបាយដោយលំបាកក្នុងកិច្ចញ៉ាំងឲ្យសិក្សាធិការសម័យបុរាណបានជឿនលឿនចំរើនលូតលាស់ តាមរយៈសាលារៀននៅតាមវត្តវាំ ។ សាលាវត្តមានបីបែប ៖ សាលាវត្តបែបទីមួយជាសាលាស្វ័យភាព (ឯករាជម្ចាស់ការខ្លួនទីពឹងខ្លួន) ដូច្នេះសាលារៀនបែបនេះ ឥតនៅក្រោមអាណាព្យាបាលរបស់យើងឡើយ ។ សាលាបែបនេះគេរាប់ទៅឃើញមាន៩៥សាលាក្នុងឆ្នាំ១៩៤៤ ដោយមានសិស្សានុ-សិស្សសរុប១០៥៨នាក់ ។ សាលាខ្លះទៀតត្រូវបានជំនួយឧបត្ថម្ភជាប្រាក់កាសនិងជាសម្ភារៈពីរដ្ឋអំណាច ។ សាលាផ្នែកនេះមានចំនួន២០នាដើមឆ្នាំ១៩៤៥ ដោយ-មានសិស្សានុសិស្ស៥៧១នាក់។ នៅទីបញ្ចប់ ចាប់តាំងពីរវាង១៥ឆ្នាំកន្លងមកហើយគេបានខ្នះខ្នែងបង្កើតចំនួនសាលារៀននៅតាមវត្តអារាមនានា ដែលគេឲ្យឈ្មោះថា «សាលាវត្តទំនើបថ្មី Ecoles Pagodes Rénovées » ដែលកិច្ចការសិក្សាត្រូវបានព្រះសង្ឃជាអ្នកផ្តល់ឲ្យ ហើយដែលព្រះសង្ឃទាំងនោះ ត្រូវបានគេបញ្ជូនឲ្យនិមន្តទៅធ្វើកម្មសិក្សាក្រឹតតែល្អប្រសើរ ( un stage de perfectionnement ) នៅទីក្រុងភ្នំពេញ, នៅខេត្តត្រាវិញ ឬនៅខេត្តសុកត្រាំង ។ ត្រង់នេះគេតោងខិតខំណែនាំផ្តល់យោបល់តាមកាលៈទេសៈដែលអាចធ្វើ ទៅបានតាមច្បាប់ ចំពោះសិក្សាធិការដែ-លមានលក្ខណៈស្ទើរសុទ្ធសឹងតាមមាគ៌ា សាសនាតែទាំងអស់ទៅហើយនោះ ។ ចំនួនសាលារៀនបែបនេះបានកើនឡើងពី ៣៧ក្នុងឆ្នាំ១៩៣០ ទៅដល់៩០ក្នុងឆ្នាំ១៩-៣៦ ហើយនិងមានរហូតទៅដល់២០៩ក្នុ ងឆ្នាំ១៩៤៤ ។ រីឯចំនួនកូនសិស្សក៏បាន

កើនឡើងជាលំដាប់លំដោយដែរ គឺពី១៥ ២៨នាក់ក្នុងឆ្នាំ១៩៣០ រហូតទៅដល់៧២-៧៨នាក់ក្នុងឆ្នាំ១៩៤៤ ។ ក្នុងចំណោមនោះ គេរាប់ឃើញមានសិស្សនារី១០៩៣នាក់ដែរ ដែលរហូតមកទល់ពេលនេះ សិស្សស្រីៗដោយសំអាងទៅលើទំនៀមទំលាប់ប្រពៃណី ត្រូវគេធ្វើឲ្យឃ្លាតឆ្ងាយពីការសិក្សា ។ នៅក្នុងដំណាលពេលជាមួយគ្នានោះ ចំនួនសាលារៀនបារាំង-ខ្មែរ ( Ecoles Officielles Franco-Khmères ) ជាផ្លូវការក៏មានមិនលើសពី១៩សាលាដែរ ហើយមានគ្រូបង្រៀនតែ៣០នាក់ប៉ុណ្ណោះ ។ ត្រង់នេះវាមានបញ្ហាមួយដែលគួរតែចងចាំក្នុងសតិអារម្មណ៍ ។ ទោះបីមានការចាត់ចែងឲ្យមានការអប់រំព្រះសង្ឃជាគ្រូបង្រៀនយ៉ាងនោះក៏ដោយ ក៏ការបង្កើត « សាលាវត្តបែបថ្មី Ecoles de pagodes Rénovées » នោះគ្រាន់តែជាមធ្យោបាយបណ្ដោះអាសន្នតែប៉ុណ្ណោះ ក៏មិនអាចជាជំនួសការសិក្សាធម្មតា ដែលមានពីរផ្នែកនោះឡើយ គឺផ្នែក ( Cycle Elémentaire : កុមារដ្ឋាន, បរិវេចនដ្ឋាន និង អាទិកដ្ឋាន ) ដែលការសិក្សាស្ថិតនៅជាភាសាខ្មែរ ។ ឯផ្នែក ( Cycle Complémentaire :មជ្ឈិមដ្ឋានទី១, មជ្ឈិមដ្ឋានទី២ និង ឧត្តមដ្ឋាន ) នោះវិញ តោងចាប់ផ្ដើមឲ្យស្គាល់ចេះអក្សរសាស្ត្រជាភាសាបារាំង ។ ក៏ប៉ុន្តែគេជួបប្រទះនឹង បញ្ហាពិបាកក្នុងការជ្រើសរើសរកគ្រូបង្រៀនបឋមសិក្សា ព្រមទាំងកិច្ចខិតខំខ្វះខ្វែង ដើម្បីបញ្ចូលការសិក្សាទៅក្នុងអាណាខេត្តទាំងឡាយរបស់ខ្មែរ (សង្គមខ្មែរសម័យបូរាណ) ។ ទាំងនេះហើយដែលធ្វើឲ្យគាំងដំណើរ ព្រោះតែកង្វះចំនួនគ្រូ ហើយនិងបុគ្គលិកមានសមត្ថភាព ។ ក្នុងន័យនេះ ខ្ញុំចង់ជំរុញសិក្សាធិការឲ្យជឿនលឿនទៅមុខ សំរាប់ជនជាតិខ្មែរនៅដែនកូសាំងស៊ីន ។ ហេតុនោះហើយបានជាចង់ឲ្យបឋមសិក្សាជាន់ដំបូង ( Ecoles Primaires Elémentaires) បានលូតលាស់ជឿនលឿនទៅមុខយ៉ាងឆាប់រហ័ស ជាហេតុញាំងឲ្យកូនខ្មែរទាំងឡាយមានវិញ្ញាបនប័ត្រ (Certificates d'Etudes) ហើយដែលពួកគេភាគខ្លះនឹងក្លាយខ្លួនទៅជាគ្រូបឋមសិក្សាជំនួយ ( Instituteurs auxiliaires ) រួចខ្លះទៀតនឹងក្លាយទៅជាគរុសិស្សជំនាន់ដំបូងបង្អស់នៅសាលាគរុវិជ្ជា ហើយដែលពួកគេត្រូវតែវិលត្រឡប់មកបំពីការងារផ្នែកសិក្សាធិការវិញ ពេលកិច្ចការអប់រំចប់សព្វគ្រប់រួចរាល់អស់ហើយ ដោយលះបង់ចោលផ្នែកកិច្ចការនយោបាយចេញ ដើម្បីចូលប្រឡូកជួយជំរុញការសិក្សាផ្នែកបឋមសិក្សា ដែលត្រូវចុះឱនថយយ៉ាងខ្លាំងនៅលើដែនដីឥណ្ឌូចិនទាំងមូល ចាប់តាំងពីមានវិបត្តិសេដ្ឋកិច្ចក្នុងរវាងឆ្នាំ១៩២៩-១៩៣៣នោះមក ។

បញ្ហាមិនត្រឹមតែទាក់ទងដោយផ្ទាល់ ឬប៉ះពាល់ជាពិសេសទៅដល់បុត្រាបុត្រីខ្មែរនៅដែនកូសាំងស៊ីន ក្នុងកិច្ចផ្ដល់នូវការសិក្សាផ្នែកបឋមសិក្សា ដែលជាសិទ្ធិរបស់ពួកគេប៉ុណ្ណោះឡើយ តែវាជាប់ទាក់ទងទាំងមូល ទៅនឹងបញ្ហាដ៏លំបាកក្នុងការ




រូបថតព្រះវិហារវត្តពោធិស្រះស្រង់ កំពង់ ( រកាថ្មី ) ( ប្រទេសកម្ពុជាក្រោម )

ជ្រើសរើសរកអ្នកចំណានៗលើសគេ ( les élites ) ទៅទៀតផង ក្នុងចំណោមជនជាតិភាគតិចខ្មែរនៅត្រង់តំបន់ទន្លេមេគង្គផ្នែកខាងក្រោម (Bas-Mékong) ក៏ដូចជានៅប្រទេសកម្ពុជាទាំងមូលផងដែរ ។ ការដែលធ្វើឲ្យអ្នកសង្កេតការណ៍ចាប់អារម្មណ៍ជាងគេនោះ គឺថាក្នុងសង្គមនេះខ្វះយ៉ាងខ្លាំងនូវក្របខ័ណ្ឌអ្នកដឹកនាំលើកលែងតែព្រះសង្ឃចេញ ។ នៅក្នុងរាជាណាចក្រខ្មែរសម័យបូរាណ ភាគច្រើនៗតែជនជាតិយួនទេ ដែលជាមន្ត្រីនៅក្នុងផ្នែករដ្ឋបាល ឬក្នុងផ្នែកកិច្ចការសាធារណៈ ហើយស្ថានភាពបែបនេះគឺចំពោះជនជាតិខ្មែរដែលត្រូវតែព្រួយបារម្ភជាងគេបង្អស់ តែហាក់បីដូចជាមិនទាន់មានការភ្ញាក់ផ្អើល ឬមានប្រតិកម្មតទល់ច្រើនណាស់ណាតែសោះ ។ នេះក៏ប្រហែលជាមានប្រភពដើមពីយូរវែងអន្លង់មកហើយក៏មិនដឹង ។ គួរកត់សំគាល់ថា ការចុះឱនថយនៃប្រទេសនេះ កើតមានឡើងនៅពេលដំណាលគ្នា នឹងសម័យកាលមួយដែលប្រទេសឥណ្ឌាត្រូវឃ្លានពានលុកលុយ ពីពួកម៉ុ-

យស៊ុលម៉ង់ (Invasions musulmanes អ្នកកាន់សាសនាមហាម៉ាត់) ។ ចាប់តាំងពីពេលដែលប្រទេសកម្ពុជាត្រូវខ្វះអ្នកក្រុមខ័ណ្ឌដឹកនាំ ប្រហែលត្រូវផ្តល់ឲ្យដោយពពួកព្រាហ្មណ៍នោះឯងហើយ ដែលភាពអាប់ឱនក៏ត្រូវធ្លាក់ចុះចាប់ផ្តើមឡើងភ្លាម ។ មានមូលហេតុខ្លះៗដែរសំរាប់យកមកផ្សះផ្សារបើទបាំងការខ្វះខាតក្នុងកិច្ចជ្រើសរើសរកអ្នកចំណានជាងគេនោះដោយបានផ្តល់នូវហេតុផលដូចគ្នានាសម័យហ្វូណានបូរាណ (dans l'ancien Fou-nan) ហើយដែលគេបានរកឃើញពពួកជនជាតិសៀម ( les Siamois ) នាពេលថ្មីៗនេះបានតតាំងទប់ទល់នឹងការក្រោកឡើងភ្ញាក់រលឹកឡើងវិញនៃប្រជាជាតិខ្មែរ នៅពេលចូលលុកលុយរាតត្បាតរបស់ខ្លួន បានកាប់សម្លាប់ឬចាប់នាំយកទៅនូវក្រុមខ័ណ្ឌអ្នកដឹកនាំខ្មែរទាំងឡាយ ។

ទោះបីយ៉ាងណាក៏ដោយ កិច្ចការជាបន្ទាន់ កិច្ចការជាចាំបាច់ គឺត្រូវផ្តល់ឲ្យដល់ជនជាតិភាគតិចខ្មែរនៅដែនកូសាំងស៊ីន នូវមធ្យោបាយគ្រប់គ្រាន់សំរាប់ជួយធានាដល់បុគ្គលិកលក្ខណៈជាមនុស្សភាព (les moyens de sauvegarder sa personna lité ) ដោយបង្កបង្កើតជាសាលារៀនសំរាប់ពួកគេ ហើយជាពិសេសទៅទៀតគោងបញ្ឈប់នូវទម្លាប់ដែលបានត្រឹមផ្តល់នូវប្រាក់កាសទ្រព្យបន្តិចបន្តួចចិញ្ចឹមខ្លួនស្ទើរមិនរស់ ដែលរមែងតែងតែផ្តល់ឲ្យដល់គ្រូបង្រៀនខ្មែរនៅតាមភូមិស្រុកទាំងឡាយនូវប្រាក់បៀវត្សតិចតួចស្តួចស្តើងណាស់ដូចជាក្នុងករណីគ្រូបង្រៀននៅដែនកូសាំងស៊ីននេះស្រាប់ ដែលក្នុងឆ្នាំ១៩៨៣គ្រូៗត្រូវបានជ្រើសរើសបានមកដោយលំបាកតែប្រាក់ខែពួកគេក្នុងការបំពេញសកម្ម- ភាពវិជ្ជាជីវៈ បូកផ្សំនឹងប្រាក់បំណាច់ ( les indemnités comprises) បានត្រឹមតែម្ភៃមួយពីយ៉ាស់ (21 piastres ប្រាក់សម័-នោះ ) ក្នុងមួយខែ ។ បញ្ហាបញ្ចូលការរៀនសូត្រទៅក្នុងសហគមជនជាតិភាគតិចទាំងនោះ មិនមែនជាបញ្ហាតែមួយគត់ដ៏សមរម្យ ដែលគេតម្រូវឲ្យយើង ប្រកបដោយសុឆន្ទៈគ្រប់គ្រាន់ប៉ុណ្ណោះឡើយ តែគោងមានថវិកាបរិបូណ៌ថែមទៅទៀត ។ អ្វីៗសព្វបែបយ៉ាងសុទ្ធតែចេញមកពីអវិជ្ជា ។ ប្រជាកសិករខ្មែរត្រូវមានសិទ្ធិក្នុងការស្វែងរកវិជ្ជា ។ ដោយមានចិត្តស្រឡាញ់យ៉ាងខ្ជាប់ខ្ជួននូវទឹកដីជាកេរ្តិ៍អាករមត៌កពីដូនតារបស់គេរាប់តំណាមកហើយនោះ ម៉្លោះហើយពួកគេឥតមានទាំងគ្រឿងសព្វាវុធយុទ្ធោបករណ៍អ្វីទាល់តែសោះ សំរាប់ការពារនូវបេតិកភ័ណ្ឌជាតិរបស់ពួកគេផង ( son patrimoine ) ដូច្នោះហើយជារឿយៗ ពួកគេត្រូវទទួលរងគ្រោះដោយការប្រើល្បិចកលដណ្តើមយក ឬដោយការប្រើកម្លាំងបាយ (spoliation)។ ព្រះសង្ឃជាអ្នកឧបត្ថម្ភគាំពារ ជាធម្មតាដល់ពពួកគេអប់រំណែនាំពួកគេឲ្យដើរតាមមាគ៌ាដ៏ល្អប្រពៃតាមផ្នែកសីលធម៌, មនុស្សធម៌, សាមគ្គីធម៌, មិនបៀតបៀនអ្នកដទៃពោលដោយខ្លីគឺថែរក្សាយ៉ាង ម៉ឺងម៉ាត់នូវទំនៀមទំលាប់ប្រពៃណីពីបូរំបូរាណកាល

តែដោយមិនបានគិតទៅ ដល់ពន្លឺនៃអនាគតដ៏រុងរឿងនៃការរស់នៅនាសម័យទំនើបនោះឡើយ ។ ពួកចាស់ព្រឹទ្ធាចារ្យ ដែលពួកគេរមែងតែងតែគោរព និងស្ទើរសួរយោបល់ផ្សេងៗនៅពេល ដែលជួបនូវឧបសគ្គដ៏លំបាកម្តងម្កាលនោះ ក៏ពួកចាស់ៗទាំងនោះបានត្រឹមតែអ្នកក្លាហានអង់អាច ប្រកាន់ខ្ជាប់ខ្ជួននូវប្រពៃណីពីបូរាណដែលឥតមានទាំងចារីកអ្វីជាក្បួនខ្នាតសោះឡើយ (ធ្វើតាមតៗគ្នា) ក៏ពួកគេទាំងនោះឥតមានអ្វីជាទីពឹងពំនាក់ផងដែរ ។ នៅចំពោះមុខនៃការចាំបាច់ដែលគ្មានចេះអត់ឱនឬលើកលែង ក្នុងការរៀបចំចាត់ចែងផ្នែកសង្គមកិច្ច ហើយដែលសេចក្តីស្មោះត្រង់របស់អ្នកទន់ខ្សោយ ត្រូវបានគេលើកយកបង្ហាញឲ្យឃើញពីការប្រយុទ្ធយកទីកន្លែង បានប្រព្រឹត្តទៅដោយតឹងតែងបំផុត គួរឲ្យព្រឺ...។

ការប៉ះទង្គិចរវាងជាតិសាសន៍ពីរខុសគ្នា ដែលមួយសកម្មមិនចេះនៅស្ងៀមរបិលរប៉ូច ដែលក្លាហានមិនញញើតញញើម ហើយដែលមួយទៀតលែងឈឺចាប់ឬខ្វល់ព្រួយ ហើយដែលជាអ្នកប្រពៃណីនិយម រមែងផ្តល់ឲ្យជារៀងរាល់ថ្ងៃ ជាអចិន្ត្រៃយ៍នូវការរំលោភគេងប្រវ័ញ្ច នូវភាពដែលជ្រួលហួសហេតុ ។ តែប្រទេសយើងគ្មានមធ្យោបាយ... មិនដឹងធ្វើយ៉ាងណា ដើម្បីគ្របសង្កត់ឬបង្ក្រាបនូវជម្លោះទាស់ទែងខ្វែងគំនិតគ្នាអស់ទាំងនេះបាន ។ ហើយដែលភារៈកិច្ចនេះត្រូវធ្លាក់ទៅលើនាយកខាងគណបេសកកម្មសហព័ន្ធទទួលបន្ទុកខាងសំរុះសំរួលអធិករ ឬជាអជ្ញាកណ្តាល (Chef de la mission fédérale d'arbitrage) ដែលត្រូវជ្រើសរើសតែង




រូបថតព្រះវិហារវត្តពោធិសាលរាជកំពង់ កសាងមុនឧកញ្ញាសឺង-គុយពលិកម្មជីវិតឆ្នាំ១៨៤១